# ព័ត៌មានកម្ពុជាថ្ងៃនេះ

៨ មេសា ២០២២

## ព័ត៌មានសំខាន់ៗ

1. បារាំង ប្តេជ្ញានឹងផ្តល់ជំនួយដើម្បីជំរុញការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីនៃក្រសួងយុត្តិធម៌ ដែលជាផ្នែកមួយនៃការកែទម្រង់ប្រព័ន្ធច្បាប់នៅកម្ពុជា។
   ប្រភព៖ ខ្មែរថាមស៍
2. អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ប្តេជ្ញាគាំទ្រកម្ពុជាលើវិស័យសក្តានុពល តាមរយៈការជំរុញធនធានមនុស្ស និងការប្រើប្រាស់ប្រព័ន្ធឌីជីថល។
   ប្រភព៖ សារព័ត៌មានថ្មីៗ
3. ពាណិជ្ជកម្មកម្ពុជា និងថៃ មានទំហំទឹកប្រាក់ប្រមាណ ១,៣ពាន់លានដុល្លារ ដែលមានការកើនឡើង ៣,៣% ក្នុងរយៈពេល ០២ខែដំបូងនៃឆ្នាំ២០២២។
   ប្រភព៖ ខ្មែរថាមស៍

## ព័ត៌មានសេដ្ឋកិច្ច

1. ធនាគារជាតិ បានបញ្ជាក់ថាការទូទាត់ប្រាក់មានការរីកចម្រើន និងអភិវឌ្ឍទៅរកការទូទាត់បែបឌីជីថល ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម។
   ប្រភព៖ AMS News
2. ធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករថាផលិតផលក្នុងស្រុករបស់កម្ពុជានឹងកើនឡើងដល់ ៥,៣% នៅឆ្នាំ២០២២ និង ៦,៥%នៅឆ្នាំ២០២៣។
   ប្រភព៖ ខ្មែរថាមស៍
3. ធនាគារពិភពលោក បានផ្តល់ជំនួយសម្រាប់ពង្រីកលទ្ធភាពចិញ្ចឹមសត្វ និងដាំដុះ ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាជន និងពង្រឹងកំណើនផលិតកម្មកសិកម្ម។
   ប្រភព៖ កោះសន្តិភាព

## ព័ត៌មាននយោបាយ

1. គ.ជ.ប ច្រានចោលការចោទប្រកាន់របស់គណបក្សប្រឆាំងដែលអះអាងថាប្រធាន គ.ជ.ប មិនមានអព្យាក្រឹត្យ និងលម្អៀងទៅខាងគណបក្សកាន់អំណាច។
   ប្រភព៖ ខ្មែរថាមស៍
2. គ.ជ.ប បានបើកកិច្ចប្រជុំ ដើម្បីពិនិត្យ និងសម្រេចលើខ្លឹមសារសៀវភៅណែនាំ និងឯកសារគោលការណ៍សម្រាប់កម្មវិធីឃោសនាបោះឆ្នោត សរុបចំនួន ១២ឯកសារ។
   ប្រភព៖ Fresh News
3. សវនាការសំណុំរឿងសន្ទិដ្ឋិភាពពាក់ព័ន្ធនឹងលោក កឹម សុខា នឹងលើកទៅក្រោយចូលឆ្នាំខ្មែរ ស្របពេលដែលមានភាពតានតឹងខ្លះៗរវាងតំណាងអយ្យការ និងមេធាវីលោកកឹម សុខា។
   ប្រភព៖ RFI

## ព័ត៌មានសង្គម

1. កម្ពុជា បានកោតសរសើរអង្គការ HALO Trust ក្នុងការចូលរួមចំណែកក្នុងសកម្មភាពមីនមនុស្សធម៌ ដោយបានផ្តល់ដីសុវត្ថិភាពពីសំណល់ជាតិផ្ទុះពីសម័យសង្គ្រាម។
   ប្រភព៖ ខ្មែរថាមស៍
2. ធនាគារព្រីនស៍ បានបណ្តាក់ទុនវិនិយោគបន្ថែម ៣៥លានដុល្លារ ដើម្បីគាំទ្រដល់ការអភិវឌ្ឍគម្រោងសាងសង់ អាកាសយានដ្ឋានអន្តរជាតិតេជោ នៅខេត្តកណ្តាល។
   ប្រភព៖ ទីភ្នាក់ងារសារព័តមានកម្ពុជា
3. គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានអំពាវនាវស្តីពីការបង្ការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នាពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរខាងមុខនេះ។
   ប្រភព៖ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា

Cambodia Development Center
info@cd-center.org
(+855) 10 950 456
www.cd-center.org

©រក្សាសិទ្ធិប្រើប្រាស់ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា | ២០២២